# បទបញ្ញាអំពីបម្រាមបផ្លាស្ទិកប្រភេទ Polystyrene

លក្ខខណ្ឌតម្រូវនៃក្រមសាលាក្រុងឡុងប៊ិចជំពូក 8.63

**វត្ថុខាងក្រោមនេះត្រូវហាមឃាត់ ក្រោមច្បាប់ក្រមសាលាក្រុង LBMC8.63**

## ប្រអប់ដាក់ចំណីអាហារ

ហាមដាក់អាហារស្រាប់ក្នុងប្រអប់ដែលមានសារធាតុដូចខាងក្រោម៖

- ស្នោ (Styrofoam™)
- ប្លាស្ទិកស្រួយ (Plastic #6)



## លក់រាយ

ហាមលក់ និងចែកចាយរបស់ធ្វើពីប្លាស្ទិកប្រភេទស្នោ Polystyrene ដូចខាងក្រោម៖

- របស់សម្រាប់ហូបអាហារ
- សម្ភារៈសម្រាប់វេចខ្ចប់
    - រួមមាន ស្នោ ឬដុំស្នោតូចរាងដូចសណ្តែកដីពោតលីង ឬសរសៃមី
- ថាដាក់សាច់ ត្រី ឬបន្លែបង្ការ និងប្រអប់ដាក់ស៊ុត
- ស្នោធុងទឹកកក ស្នោញាត់តុក្កតា ស្នោញាត់ខ្នើយអង្គុយ និងគ្រាប់អង្កាំ



## បំពង់បឺត

- បំពង់បឺតមិនត្រូវធ្វើពីជ័រប្លាស្ទិក និងមិនត្រូវឲ្យទៅភ្ញៀវនោះឡើយ លើកលែងតែភ្ញៀវសុំ
    - អាចឲ្យបំពង់បឺតជ័រប្លាស្ទិកទៅអតិថិជន បើជាការចាំបាច់ដែលត្រូវអនុវត្តតាមលក្ខខណ្ឌ សម្រាប់ជនពិការ



LongBeach.gov/FFLB
FoamFreeLB@longbeach.gov
@LBRecycles

# របស់សម្រាប់ហូបអាហារ ប្រើតែមួយដង

លក្ខខណ្ឌតម្រូវនៃច្បាប់រដ្ឋ AB 1276

## ច្បាប់រដ្ឋ AB 1276

ច្បាប់រដ្ឋកំណត់និយមន័យរបស់សម្រាប់ញ៉ាំអាហារតែមួយដង ថាជាស្លាបព្រា សម កាំបិត ចង្កឹះ ប្រអប់និងកញ្ចប់ដាក់ទឹកជ្រលក់ បំពង់បឺត ប្រដាប់កូរ ស្លាបព្រាកូ និងប្រដាប់ដោតផ្លែឈើលើកែវស្រា

- រាល់របស់សម្រាប់ញ៉ាំអាហារដែលប្រើតែមួយដងទាំងអស់ ត្រូវឲ្យអតិថិជនតែក្នុងករណីដែលអតិថិជនសុំវាតែប៉ុណ្ណោះ
- បើអតិថិជនសុំរបស់សម្រាប់ញ៉ាំអាហារចម្អិតស្រាប់  គឺឲ្យតែមួយប៉ុណ្ណោះ
- កន្លែងលក់រាយចំណីអាហារ មិនអាចចងប្រដាប់ហូបអាហារមួយដុំជាប់គ្នា
- សម្រាប់ភាគីទីបីដែលដឹកជញ្ជូនអាហារទៅក្រៅ និងការបញ្ជាទិញ ត្រូវផ្តល់ជម្រើសដល់អតិថិជន ឲ្យស្នើសុំរបស់សម្រាប់ញ៉ាំអាហារប្រើតែមួយដង នៅលើបញ្ជីរាយមុខម្ហូប







## ធនធាន និងព័ត៌មានបន្ថែមទៀត

- សូមសួរអ្នកផ្គត់ផ្គង់របស់អ្នកបច្ចុប្បន្ន ដើម្បីរកមើលជម្រើសផ្សេងពីការប្រើស្នោក្នុងការវេចខ្ចប់
- អង្គការ **LB Reuses** ជាសម្ព័ន្ធអាជីវកម្ម និងអង្គការនៅក្នុងទីក្រុងឡុងប៊ិច ដែលលើកទឹកចិត្តឲ្យពលរដ្ឋយករបស់សម្រាប់ញ៉ាំអាហារ ដែលប្រើម្តងទៀតបាន មកតាមខ្លួន ដើម្បីប្រើប្រាស់សម្រាប់ញ៉ាំអាហារ និងភេសជ្ជៈដែលទិញពីហាង។
- សូមចូលរួមក្នុងក្រុមអាជីវកម្មនេះ ដោយព្រមប្រើប្រាស់របស់ដែលប្រើបានម្តងទៀត និងអ៊ីម៉េល **LBReuses@gmail.com** ដើម្បីទទួលបានស្លាកបិទនៅបង្អួចហាង។
- សម្រាប់ព័ត៌មានបន្ថែមអំពីច្បាប់រដ្ឋនៅថ្នាក់មូលដ្ឋាន ពាក់ព័ន្ធនឹងអាជីវកម្មរបស់បងប្អូន សូមចូលមើលគេហទំព័រ **Longbeach.gov/FFLB**

Longbeach.gov/FFLB
FoamFreeLB@longbeach.gov
@LBRecycles